**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល

គម្រោងពង្រឹងផលិតភាពស្រះតាមរយ:វារីវប្បកម្ម ដោយពឹងលើចំណីស្លែពេរីហ្វីតុន នៅសហគមន៍ខេត្តកំពត

Project: Improving Pond Productivity Through Introducing Periphyton-Based Aquaculture In Kampot Community-CARF-RUA 256

# សៀវភៅបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារដោយ ពឹងលើចំណីស្លែតោងនឹងសម្រាស់នៅក្នុងស្រះ

**Manual on Periphyton-Based Family Aquaculture In Pond With Substrates**



**ហុក សែនសម្ភា**

**ម៉ែន សុខា**

**ហួត គង់ហ៊ាង**

*ផ្តល់មូលនិធិគម្រោងដោយ CARF*

Cambodian Agricultural Research Fund

*សម្របសម្រួលគម្រោងដោយ*

Cambodia Agricultural Value Chain Program (CAVAC)

**២០១២**

អាស័យដ្ឋាន៖ ចំការដូង សង្កាត់ដង្កោ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រ ២៦៩៦

Phone: 023 219 753 E-mail: rector_office@rua.edu,kh

# មាតិកាអត្ថបទ

ទំព័រ


អារម្ភកថា ..........................................................................ក

សេចក្តីថ្លែងអំណរគុណ ..............................................................ខ

អ្វីទៅជាស្លែពេរីហ្វីតុន(Periphyton)? ..........................................១

១.សារៈប្រយោជន៍របស់សម្រាស់ និងពេរីហ្វីតុនក្នុងការចិញ្ចឹមត្រី ........២

១.១.សារៈប្រយោជន៍របស់សម្រាស់ក្នុងការចិញ្ចឹមត្រី .......................២

១.សារៈប្រយោជន៍របស់សម្រាស់ក្នុងការចិញ្ចឹមត្រី ..........................៣

២.បច្ចេកទេសចិញ្ចឹមត្រីពឹងលើចំណីស្លែពេរីហ្វីតុន ..........................៤

២.១.ការរៀបចំផែនការចិញ្ចឹមត្រី ..................................................៤

២.២.ការរៀបចំសម្អាតស្រះចិញ្ចឹមត្រី ............................................៤

២.៣.ការប្រើប្រាស់កំបោរ និងដាក់ជីទ្រាប់បាតស្រះ .........................៥

២.៤.ការបូមទឹកបញ្ចូលស្រះ .........................................................៦

២.៥.ការរៀបចំដាក់សម្រាស់ .........................................................៧

២.៥.១.សម្រាស់ឬស្សី ...................................................................៧

២.៥.១.សម្រាស់មែកអំពិលទឹក ...................................................៨

២.៦.ការលែងកូនត្រីពូជដាក់ចិញ្ចឹម ...............................................៩

២.៧.ការបង្កើតចំណីធម្មជាតិតាមរយៈការប្រើជី ...........................១០

២.៨.ការប្រមូលផលត្រី ...........................................................១១

រូបភាពសកម្មភាពចិញ្ចឹមត្រីពឹងលើចំណីពេរីហ្វីតុន

# អារម្ភកថា

យោងទៅលើ ស្ថានភាពនៃវិស័យវារីវប្បកម្មជាលក្ខណៈគ្រួសារ នៅក្នុងប្រទេសកម្ពុជា កំពុងតែរីកដុះដាលយ៉ាងសន្ធឹកសន្ធាប់ពីមួយថ្ងៃទៅមួយថ្ងៃ ទាំងបរិមាណ និងបច្ចេកទេសចិញ្ចឹម។ ជាការពិតណាស់ ការចិញ្ចឹមត្រី ត្រូវផ្អែកលើចំណី ដែលរួមមានចំណីបន្ថែម និងចំណីធម្មជាតិ។ ចំណីបន្ថែម ដែលកសិករចិញ្ចឹមបានផ្តល់ឲ្យត្រី មិនបានទៀងទាត់ ទៅតាមបច្ចេកទេសនោះឡើយ ហើយចំណីទាំងនោះ មានតម្លៃថ្លៃ ធ្វើឲ្យកសិករក្រីក្រចិញ្ចឹមត្រីទទួលបានទិន្នផលមិនសមស្របតាមបំណង និងមានកសិករមួយចំនួនធំ បានបោះបង់ការចិញ្ចឹមនេះតែម្តង។

ដើម្បីឲ្យកសិករអាចបន្តការចិញ្ចឹមត្រីបាន គំរោងសិក្សាស្រាវជ្រាវស្តីពី «**ការពង្រឹងផលិតភាពស្រះតាមរយៈការចិញ្ចឹមត្រី ដោយប្រើស្លៃពេរីហ្វីតុន នៅសហគមន៍ជនបទខេត្តកំពត**» របស់សាកវិទ្យាល័យភូមិន្ទកសិកម្ម(ចំការដូង) បានស្រាវជ្រាវទៅលើការចិញ្ចឹមត្រីដោយពឹងលើគោលការណ៍ធម្មជាតិដោយចំណាយដើមទុនតិច ហើយទទួលបានផលយ៉ាងគាប់ប្រសើរ។

សៀវភៅនេះ មានអធិប្បាយអំពីបច្ចេកទេសចិញ្ចឹមត្រី ដោយពឹងលើស្លៃពេរីហ្វីតុនតោងព័ទ្ធនឹងសម្រាស់នៅក្នុងស្រះ ដើម្បីជាឯកសារជំនួយដល់កសិករចិញ្ចឹម ដែលមានបំណងចង់ចិញ្ចឹមត្រីដោយចំណាយដើមទុនតិចតួចបំផុត និងមិនផ្តល់ចំណីបន្ថែមឡើយ។ កសិករចិញ្ចឹមត្រីអាចអាន និងធ្វើការពិភាក្សាគ្នាតាមភូមិ ឬតំបន់នីមួយៗ ដោយយកសៀវភៅបច្ចេកទេសនេះជាបង្អែក។ បើមានចម្ងល់ ឬចំនុចមិនច្បាស់លាស់ អាចសួរយោបល់ប្រឹក្សាជាមួយក្រុមអ្នកនិពន្ធ តាមអាស័យដ្ឋានដែលមានភ្ជាប់នឹងសៀវភៅនេះស្រាប់។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២

**តំណាងក្រុមអ្នកនិពន្ធ**

**ហុក សែនសម្ភា**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅបច្ចេកទេសចិញ្ចឹមត្រី ដោយពឹងផ្អែកលើស្លែពៃរីហ្វីតុនគោងព័ទ្ធនឹងសម្រាស់នៅក្នុងស្រះ បានបោះពុម្ពឡើងក្រោមជំនួយថវិកាពី មូលនិធិស្រាវជ្រាវកសិកម្មកម្ពុជា (CRAF) របស់ប្រទេសអូស្ត្រាលី ដោយមានការគាំទ្រជំនួយមតិយោបល់ពីគំរោងខ្សែសង្វាក់តម្លៃផលិតកម្មកសិកម្មកម្ពុជា (CAVAC)។

ក្រុមអ្នកនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ៖

- **បណ្ឌិត ក្រេច មាសស្មៃនី** (Dr. Crag Meas Smeiner) ជាអ្នកគ្រប់គ្រងគម្រោង CARF,
- **លោក និន ចរិយា** ជាអ្នកសម្របសម្រួលគម្រោង CARF,
- **លោក ឈូក បូរិន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រជលផល និងជាជំនាញការបច្ចេកទេសរបស់គម្រោងស្រាវជ្រាវ ព្រមទាំងសាស្ត្រាចារ្យ និងនិស្សិត នៃមហាវិទ្យាល័យវិទ្យាសាស្ត្រជលផល នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ដែលបានចូលរួមអនុវត្តន៍ចិញ្ចឹមស្រាវជ្រាវចងក្រងសៀវភៅនេះ។

សូមថ្លែងសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះ លោក លោកស្រី បំរើការនៅខណ្ឌរដ្ឋបាលជលផលកំពត និងអង្គការអភិវឌ្ឍន៍ចំរុះ (FDO) ដែលបានសហការណ៍ទាំងកំលាំងកាយ និងស្មារតី ក្នុងការជ្រោមជ្រែងដំណើរការគម្រោងនេះ ហើយថ្លែងសេចក្តីដឹងគុណយ៉ាងកក់ក្តៅបំផុតចំពោះកសិករដៃគូចិញ្ចឹមនៅខេត្តកំពត **លោកអ៊ុំស្រី ឆាយ លៀប** និង **លោកពូ ស៊ិន គន** នៅឃុំក្រាំងស្នាយ ស្រុកឈូក។

# អ្វីទៅជាស្លែពេរីហ្វីតុន (Periphyton) ?

__ស្លែពេរីហ្វីតុន__ គឺជាសមាសភាពរុក្ខជាតិ និងសត្វអតិសុខុមប្រាណស៊ាំញាំ ដែលរស់នៅតោង ឬព័ទ្ធលើវត្ថុនានា ដែលលិចក្នុងទឹក រួមមាន៖

- ប្រូតូសូអែរ(protozoans)
- បាក់តេរី (bacteria)
- ផ្សិត (fungi)
- សារាយ (algae)
- សត្វប្លង់តុងរ៉ូទីហ្វែរ (rotifers)
- ដង្កូវដូចឈ្លើង (annelids)
- កូនញាស់សត្វល្អិត
- ពួកកំពីស ខ្យង ខ្ចៅ (Crustaceans)
- សារធាតុសរីរាង្គ (organic substances)



☺ វត្ថុដែលស្លែពេរីហ្វីតុន តោងឬរុំព័ទ្ធលើ ដូចជា មែកឈើ, រុក្ខជាតិទឹក, ដុំឬផ្ទាំងថ្ម, បង្គោលឬស្សី, ដី ជាដើម។

# ១. សារៈប្រយោជន៍របស់សម្រាស់ និងពៃរីហ្វីតុនក្នុងការចិញ្ចឹមត្រី

## ១.១ សារៈប្រយោជន៍របស់សម្រាស់ក្នុងការចិញ្ចឹមត្រី

សម្រាស់មានប្រយោជន៍មួយចំនួន សម្រាប់ការចិញ្ចឹមត្រី ដូចជា៖

- ជាទម្រសម្រាប់ពពួកពៃរីហ្វីតុន
- ជាជម្រកសប្បនិម្មិតរបស់ត្រី និងសត្វរស់នៅក្នុងទឹកដទៃៗទៀត
- ការពារពីការលួចអូស ឬបង់សំណាញ់

## ១.២ សារៈប្រយោជន៍របស់ពៃរីហ្វីតុនក្នុងការចិញ្ចឹមត្រី

ពពួកពៃរីហ្វីតុន មានប្រយោជន៍ណាស់ ចំពោះពពួកត្រី និង ប្រព័ន្ធបរិស្ថានទឹក ជាពិសេសក្នុងការចិញ្ចឹមត្រី ដោយរួមមាន ៖

- ផ្តល់ជាចំណីត្រី ជាពិសេសពពួកត្រីស៊ីចម្រុះ
- ផ្តល់អុកស៊ីសែនដល់មជ្ឈដ្ឋានទឹកគ្រប់ទីកន្លែង
- ជួយសម្អាតទឹក
- គ្មានការកើនឡើងនៃសារធាតុសរីរាង្គស្អុយរលួយនៅស្រទាប់បាត
- រក្សាលំនឹងបណ្តាញខ្សែអាហារ។



រូបទី១. ស្លែពៃរីហ្វីតុនតោងនឹងមែកឈើ

(ប្រភព: Agromisa Foundation and CTA, Wageningen, 2008)



រូបទី២. ស្លែពៃរីហ្វីតុនរុំព័ទ្ធនឹងបង្គោលឫស្សី

## ២. បច្ចេកទេសចិញ្ចឹមត្រីពីងលើចំណីស្លៃពៃរីហ្វីតុន

### *២.១ ការរៀបចំផែនការចិញ្ចឹមត្រី*

**ការចិញ្ចឹមត្រីចំរុះជាលក្ខណៈគ្រួសារ** ត្រូវមានដាក់សម្រាប់ឬស្សី ឬ សម្រាប់មែកអំពិលទឹក និងមិនផ្តល់ចំណីបន្ថែម ប៉ុន្តែត្រូវផ្តល់ជីដើម្បីបង្កើនការកកើតចំណីធម្មជាតិ ជាពិសេស ស្លៃពៃរីហ្វីតុន ។ ការចិញ្ចឹមនេះ មានរយៈពេលពី ៥ ទៅ ៦ ខែ ដោយចាប់ផ្តើមនៅពេលមានទឹកគ្រប់គ្រាន់នៅក្នុងស្រះ (ដើមរដូវវស្សា)។ ឧបមាថា មានស្រះមួយទំហំ ២០០ ម៉ែត្រការ៉េ (បណ្តោយមានប្រវែង ២០ ម៉ែត្រ, ទទឹងមានប្រវែង ១០ ម៉ែត្រ និងជម្រៅមធ្យម ១,៥ ម៉ែត្រ) ។

ដំណើរការរៀបចំការចិញ្ចឹម មានតាមលំដាប់លំដោយ ដូចខាងក្រោម៖

### *២.២ ការរៀបចំសម្អាតស្រះចិញ្ចឹមត្រី*

មុននឹងធ្វើការចិញ្ចឹមត្រី ស្រះត្រូវបានជួសជុលកែលំអរជាថ្មី និងសម្អាតដោយចាំងស្មៅដែលដុះនៅស្រទាប់បាតស្រះអោយអស់ ហើយកាប់សំអាតព្រៃឬរុក្ខជាតិនានា ដែលដុះនៅក្នុងស្រះ និងនៅលើភ្លឺស្រះឲ្យបានស្អាត ព្រមទាំងស្តារដីបាតស្រះទប់ ភ្លឺស្រះឲ្យបានស្អាតល្អ ដើម្បីកុំអោយវាលិចទឹកនៅរដូវវស្សា ។ ម្យ៉ាងទៀត បើស្រះដែលមានទឹក ត្រូវបូមពង្រីង ហើយស្តារភក់ចេញ និងសំអាតស្មៅអោយស្អាតល្អមុនដាក់កូនត្រីពូជចិញ្ចឹមតាមស្រះចិញ្ចឹមនីមួយៗ ។

## ២.៣ ការប្រើប្រាស់កំបោរ និងដាក់ជីទ្រាប់បាតស្រះ

ការប្រើប្រាស់កំបោរ គឺដើម្បីសម្លាប់ពពួកមេរោគផ្សេងៗ និងពពួកសត្វចង្រៃមួយចំនួនដែលស៊ីត្រីជាអាហារ និងធ្វើឲ្យកាក់សំណល់ផ្សេងៗ ឆាប់រលួយ កាត់បន្ថយភាពល្អក់នៃទឹកស្រះ។ល។



⬩បរិមាណកំបោរ គួរប្រើប្រាស់ចំនួន ៥ គីឡូក្រាមក្នុង ១០០ ម៉ែត្រការ៉េ នៃផ្ទៃស្រះ ហើយហាលស្រះអោយវាត្រូវពន្លឺថ្ងៃ រយៈពេល ៣ ថ្ងៃ ទើបបូមទឹកបញ្ចូលស្រះក្នុងជម្រៅ ០,៥ ម៉ែត្រ និងដាក់ជី។

⬩បន្ទាប់មក ត្រូវកំណត់បរិមាណជី និងធ្វើការដាក់ជី ដើម្បីផ្តល់សារជាតិចិញ្ចឹមរុក្ខជាតិប្លង់តុង ក៏ដូចជា ការកកើតស្លែពៃរីហ្វីតុន ដោយរក្សាទុកក្នុងរយៈពេល ៣ ថ្ងៃ ទើបបំពេញទឹកស្រះ ។ ប្រភេទជី ដែលប្រើ រួមមាន ៖

⇒ ជីលាមកសត្វប្រើក្នុងបរិមាណ ២៥ គក្រ ក្នុង ១០០ ម៉ែត្រការ៉េ ឬ

⇒ ជីអសរីរាង្គ ឬជីគ្រាប់ គឺ ជីអ៊ុយរ៉េ និងជីដេអាប៉េ (DAP) ក្នុងបរិមាណ ០,៥ គក្រ ក្នុង ១០០ ម៉ែត្រការ៉េ ដោយដាក់រៀងរាល់ ១ ទៅ ២ សប្តាហ៍ម្តង រហូតដល់ប្រមូលផល។

<u>**រូបមន្តគិតបរិមាណកំបោរ:**</u>

**បរិមាណកំបោរ = ក្រឡាផ្ទៃស្រះ X បរិមាណកំបោរដែលត្រូវប្រើ (ឬ បទដ្ឋាននៃការប្រើកំបោរ)**

<u>**ឧទាហរណ៍:**</u> *ក្រឡាផ្ទៃស្រះ ២០០ ម៉ែត្រការ៉េ និងបទដ្ឋានប្រើកំបោរ ៥ គក្រ. ក្នុង១០០ ម៉ែត្រការ៉េ នោះចំនួនកំបោរត្រូវបាចក្នុងស្រះនេះ គឺ៖ (២០០ x ៥ គក្រ) / ១០០ =* ***១០ គក្រ***

## ២.៨ ការបូមទឹកបញ្ចូលស្រះ

ក្រោយពីបានបាចកំបោរ និងដាក់ជីលាមកសត្វរួចមករយៈពេល ៣ ថ្ងៃ ស្រះនេះ ត្រូវបានបូមទឹកបញ្ចូលឲ្យបានជម្រៅប្រហែលជា ០,៥ ម៉ែត្រ ងាយស្រួលក្នុងការរៀបចំបោះបង្គោលឬស្សី ឬដាក់មែកអំពិលទឹកក្នុងស្រះចិញ្ចឹមរបស់លោកអ្នក ។



រូបភាពទី៤. សកម្មភាពបូមទឹកបញ្ចូលស្រះចិញ្ចឹមត្រី មុននឹងដាក់សម្រាស់

## ២.៩ ការរៀបចំដាក់សម្រាស់

### ២.៩.១ សម្រាស់ឬស្សី

សម្រាស់ឬស្សីស្រុក គឺត្រូវយកដើមឬស្សី ដែលមានអង្កត់ផ្ចិត ៦ ទៅ ៨ ធឹង (សង់ទីម៉ែត្រ) មកកាត់វាជាកង់ៗ ដោយក្នុងមួយកង់ៗមានប្រវែងពី ១,៣-១,៥ ម៉ែត្រ។ បន្ទាប់មក ត្រូវសម្រួចចុងវាអោយស្រួច ទើប



យកវាទៅបោះនៅក្នុងបាតស្រះដោយបញ្ឈរត្រង់ ក្នុងចំនួន ៥ បង្គោល ក្នុង ១ ម៉ែត្រការ៉េ (ឧបមាថា: សរុបក្នុងមួយស្រះ អស់ចំនួន ៥០០ បង្គោល ស្មើនឹង ១០០ ម៉ែត្រការ៉េ ពេលបោះដាក់ស្តែងតែ ២០០ បង្គោលប៉ុណ្ណោះ)។ បន្ទាប់ពីរៀបចំបោះ បង្គោលឬស្សីរួចហើយ ត្រូវបញ្ចូលទឹកដាក់បំពេញស្រះដោយរក្សាទុករយៈពេល ២ អាទិត្យ មុននឹងដាក់កូនត្រីពូជចូលចិញ្ចឹមក្នុងស្រះ។




រូបភាពទី៥. ការរៀបចំដាក់សម្រាស់បង្គោលឬស្សី

## ២.៨.២ សម្រាស់មែកអំពិលទឹក

សំរាប់សម្រាស់មែកអំពិលទឹក គឺ ត្រូវយកមែករបស់វាទៅដាក់តំរៀបគ្នាជាជួរនៅក្នុងស្រះ ស្មើនឹង ៥០% នៃផ្ទៃស្រះ ។ ដោយមែកអំពិលទឹកបែកសាខាច្រើនដូច្នេះ ត្រូវប្រើអស់ប្រហែល ៣០ មែក សំរាប់ស្រះទំហំ ២០០ ម៉ែត្រការ៉េ ដែលក្នុង ១ មែកៗ មានប្រវែងពី ១,៣-១,៥ ម៉ែត្រ។



បន្ទាប់ពីរៀបចំមែកអំពិលទឹករួចហើយ ត្រូវបូមទឹកដាក់បំពេញក្នុងស្រះនីមួយៗ អោយពេញទុករយៈពេល ២ អាទិត្យ មុននឹងដាក់កូនត្រីពូជចូលក្នុងស្រះចិញ្ចឹម ដូចដាក់សម្រាស់ឬស្សីដែរ។



រូបភាពទី៦. ការរៀបចំដាក់សម្រាស់មែកអំពិលទឹក

## ២.៦ ការលែងកូនត្រីពូជដាក់ចិញ្ចឹម

ក្នុងការធ្វើចិញ្ចឹមនេះ កូនត្រីពូជសំរាប់ដាក់ចិញ្ចឹមចំរុះ មានដូចជា កូនត្រីទីឡាព្យា កូនត្រីឆ្ពិន កូនត្រីកាបឥណ្ឌា កាបស ជាដើម ។

ម៉្យាងទៀតដង់ស៊ីតេដាក់ចិញ្ចឹមមានចំនួន ២ ក្បាល ក្នុងមួយម៉ែត្រការ៉េ (៥ ក្បាល/ម៉ែត្រការ៉េ បើផ្តល់ចំណីបន្ថែម) ហើយការលែងកូនត្រីនេះគួរតែតាមសមាមាត្រដូចខាងក្រោម៖

<u>ជាឧទាហរណ៍:</u>

- កូនត្រីទីឡាព្យាដាក់ ៧០ ភាគរយ នៃបរិមាណសរុប
- កូនត្រីឆ្ពិនដាក់ចំនួន ១៥ ភាគរយ នៃបរិមាណសរុប និង
- កូនត្រីកាបឥណ្ឌាដាក់ចំនួន ១៥ ភាគរយ នៃបរិមាណសរុប

ដូច្នេះ តាមសមាមាត្រខាងលើ កូនត្រីដែលត្រូវដាក់ចិញ្ចឹមក្នុងស្រះដែលមានផ្ទៃ ២០០ ម៉ែត្រការ៉េ គឺកូនទីឡាព្យា ២៨០ ក្បាល ឆ្ពិន ៦០ ក្បាល និង កាបឥណ្ឌា ៦០ ក្បាល។





រូបភាពទី៧. ការលែងកូនត្រីពូជក្នុងស្រះចិញ្ចឹម

## ២.៧ ការបង្កើតចំណីធម្មជាតិតាមរយៈការប្រើជីផ្សេងៗ

សម្រាប់ជីលាមកសត្វ ឬ ជី ដេ អា ប៉េ និង **ជីអ៊ុយរ៉េ** ត្រូវបានប្រើប្រាស់ក្នុងគោលបំណង់ដើម្បីបង្កើតចំណីធម្មជាតិក្នុងស្រះ ជាពិសេស ស្លៃពៃរីហ្វីតុនរុំព័ទ្ធនឹងសម្រាស់សំរាប់ផ្គត់ផ្គង់ជាចំណីឲ្យត្រីស៊ីជាប្រចាំថ្ងៃ ។

**<u>វិធីប្រើ៖</u>**

- ក្រោយពីលែងកូនត្រីក្នុងស្រះ គឺត្រូវប្រើជី ២ សប្តាហ៍ម្តង នៅខែទី១
- បន្ទាប់មក ត្រូវប្រើជី ១ សប្តាហ៍ម្តង ចាប់ខែទី២ ទៅ រហូតដល់ប្រមូលផល

**គួរសង្កេតផងដែរចំពោះពណ៌ទឹកស្រះ ចាប់ពីខែទី២ នេះ បើទឹកមិនសូវមានពណ៌បៃតង គួរដាក់ជីបន្ថែម មិនចាំបាច់តាមពេលកំណត់ទុកនោះឡើយ។**

**<u>បរិមាណជីត្រូវប្រើ៖</u>**

- ចំនួនជីគ្រាប់ប្រើសរុប ៥០ គីឡូក្រាម ក្នុង ១ ហិចតា ឬ ១០០០០ ម៉ែត្រការ៉េ

⇒ មានន័យថា ៥ ខាំ ឬ កន្លះគីឡូក្រាម ក្នុង ១០០ ម៉ែត្រការ៉េ នៃផ្ទៃស្រះ

ជីអ៊ុយរេ (Urea) ចំនួន ៣ ខាំ
\+ ជីដេអាប៉េ (DAP) ចំនួន ២ ខាំ

---

សរុបជីដែលត្រូវប្រើ **៥ ខាំ**

- បើប្រើជីលាមកសត្វ ប្រើក្នុងចំនួន ២៥០០គីឡូក្រាម ក្នុង ១០០០០ ម៉ែត្រការ៉េ

⇒ មានន័យថា **២៥ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការ៉េ** នៃផ្ទៃស្រះ

**<u>ចំណាំ:</u> ប្រភេទជីទាំងពីរនេះ ប្រើមួយណាក៏បាន។**

<u>របៀបបាចជីគ្រាប់ក្នុងស្រះដែលមានត្រី</u>

១.កូរជីជាមួយទឹកឲ្យរលាយសព្វ



២. ដួសទឹកជីជះក្នុងស្រះ ឲ្យបានសព្វផ្ទៃស្រះ ហើយធ្វើនៅពេលថ្ងៃមានពន្លឺគ្រប់គ្រាន់



## ២.៨ ការប្រមូលផលត្រី

ក្រោយពីដាក់កូនត្រីចិញ្ចឹមមក រហូតដល់រយៈពេល ៥ ទៅ ៦ ខែ ឬ ១៥០ ទៅ ១៦០ ថ្ងៃ យើងអាចប្រមូលផលត្រីបាន ទៅតាមតម្រូវការ។

ការប្រមូលផលត្រីនេះ គឺ អាស្រ័យទៅតាមចំណង់ចំណូលចិត្តរបស់អស់លោកអ្នក។ ឧបករណ៍ សំណាញ់ អួនអូស ឬ ម៉ាស៊ីនបូមពង្រីង ត្រូវបានគេប្រើសម្រាប់ចាប់យកត្រីតាមតម្រូវការ។



- បង់សំណាញ់





- អូសដោយអួន



- បូមពង្រីងស្រះដោយម៉ាស៊ីន

## រូបភាពសកម្មភាពទាក់ទងនឹងការចិញ្ចឹមត្រីពឹងចំណីស្លែពៃរីហាវីតុន

